FIRST 5 CALIFORNIA

អាយុ ២ ឆ្នាំ ទៅ ៤ ឆ្នាំ

ការរៀនសូត្រ ចាប់ផ្តើមតាំងពីក្មេងវ័យ សង្ឃឹមចង់បានអ្វីខ្លះ

នៅពេលក្មេងម្នាក់មានអាយុ ២ ទៅ ៤ ឆ្នាំ និងរបៀបដែលអ្នកអាចជួយក្មេងម្នាក់ឲ្យធំធាត់ និងរៀនសូត្រ

អាយុ ២ ទៅ ៣ ឆ្នាំ
នៅអាយុនេះ ក្មេងៗ :

- រៀនសំគាល់អ្នកផ្សេងៗ មានចិត្តជាយ៉ាងណាបានច្រើនជាបង្គរ ។
- អាចជាមានចិត្តមានៈ និងម�ៅច្រើន ។
- អាចនឹងសប្បាយលេងជុំគ្នា ជាមួយនឹងក្មេងៗឯទៀត ។
- អាចចូលចិត្តហក់លោត ផ្លោះ ក្រឡាប់ចុះ ក្រឡាប់ឡើង និងចូលចិត្តឡើងឬតោង ។
- ពុតធ្វើជាលេងយ៉ាងច្រើន ។
- រៀនពាក្យថ្មីៗយ៉ាងច្រើន ។
- រៀបពាក្យបញ្ចូលគ្នា ជាពីរបី ឬបួនឃ្លា ។

នៅអាយុនេះ ក្មេងៗ

- រៀនពាក្យកាន់តែច្រើនឡើងៗ ។ ប្រើគំនូរ ស្បៃវណ្ណ ណ្ឌេង និងភ្លេង ។
- សាកធ្វើការផ្សេងៗដោយខ្លួនគេ ដូចជាស្លៀកពាក់ខោអាវជាដើម ។
- គូរគំនូរជាមួយដីសពណ៌ និងលេងជាមួយក្រដាសរឹងៗ ដំរៀបជារូប ។
- សង់អ្វីមួយ ហើយធ្វើពុត ។
- លេងជាមួយក្មេងៗឯទៀត ។ រៀនស្គាប់ ហើយចាំដល់ផ្ទៃខ្លួន ។
- លេង ហក់លោត និងរត់ ។

ក្មេងៗក៏អាច :

- សប្បាយនឹងការពិសោធន៍ថ្មី ។
- ចាប់ផ្តើមស្លៀកពាក់ ។ អាចជានឹងត្រូវការជួយឲ្យចងខ្សែស្បៃកជើង និងបិទឡេវ ។
- ចាប់ផ្តើមមានសេចក្តីភ័យខ្លាច (“ម៉ាក់មានសត្វអ្វីធំណាស់នៅក្រោមគ្រែខ្ញុំ”) ។
- អាចជានឹងនឹកស្រមៃមានមិត្តសំឡាញ់ ។
- ចូលចិត្តរត់ ផ្លោះ ហក់ត្រង្គំជើងពីរ ចាប់បាល់ និងរពឹសនៅមិនស្ងៀម ។
- ចាប់ផ្តើមនិយាយដោយពេញឃ្លា ។
- មានការត្រួតត្រាច្រើនទៅលើដៃ និងត្រួតត្រាលើសាច់ដុំ ។
- សាកធ្វើតាមរបៀបផ្សេង ដើម្បីកំណើតខ្លួនរបស់គេ ។

ផ្តល់សេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ ដល់ក្មេងៗ ។

- អានស្បៃវណ្ណ ច្រៀងចំរៀង និងនិយាយជាមួយកូនៗ រៀងរាល់តែថ្ងៃ ។
- សំរបតាមសេចក្តីត្រូវការរបស់កូនៗ ដោយមិនយឺតយូរណ៏ ។
- ការពារកូនដ៏ជ្រលក្ខណ៏ ឲ្យបានញឹកញាប់ ។
- ធ្លើយសំរែកយំរបស់កូនដ៏ជ្រ ហើយធ្លើយសំណួរកូនរបស់អ្នក ។

ធ្វើឲ្យកន្លែងសំរាប់ក្មេងៗលេង ប្រកបដោយក្តីសុខសាន្ត ។

- ផ្តល់ពេលវេលាឲ្យកូនៗរត់ ហក់លោត និងរាំរែក ។
- បណ្តាយកូនៗឲ្យគូរគំនូរ ឬលេងជាមួយដុំឈើកង់ៗ និងបន្ទះក្រដាសរឹងៗ ដំរៀបជារូបផ្សេងៗ ។
- ផ្តល់ឱ្យកាសឲ្យកូនៗ ដើម្បីធ្វើការអ្វីមួយដោយខ្លួនឯង ។

វាក៏ជាការល្អផងដែរ ដើម្បី :

- រៀបចំពេលវេលា ដើម្បីលេងជាមួយក្មេងៗឯទៀត ។
- អនុញ្ញាតឲ្យកូនៗមានការជ្រើសរើសខ្លះ ។
- ត្រូវមានចិត្តសប្បុរស និងមានការថ្នាក់ថ្នម ធ្វើជាគំរូដល់កូនៗ ។

នៅអាយុនេះ ក្មេងៗត្រូវការមានឱ្យកាស ដើម្បី :

- ដំរៀបក្រដាសរឹងៗជារូបភាព ឬផ្ទាត់ពណ៌ និងគូសលេង ។
- ធ្វើការជាច្រើនទៀតដោយខ្លួនគេ ដូចជាស្លៀកពាក់ខោអាវ ជាដើម ។
- គេច្រៀង និយាយ និងរៀនពាក្យថ្មីទៀត ។
- លេងជាមួយក្មេងៗឯទៀត ។
- ទៅកន្លែងសួនលេង ទៅបណ្ណាល័យ ទៅផ្ទះខ្សាច់ ទៅសួនសត្ត ឬទៅកន្លែងគួរឲ្យចាប់ចិត្តផ្សេងៗទៀត ។

អាយុ ៣ ទៅ ៤ ឆ្នាំ
នៅអាយុនេះ ក្មេងៗ

- ចាប់ផ្តើមលេងជាមួយក្មេងៗឯទៀត ។
- អាចនឹងចេះចាំដល់ផ្ទៃខ្លួន និងចែកគ្នា ។
- មានក្តីរាក់ទាក់ និងចេះជ្ជ៏អ្វីទៅគេ ។
- ចាប់ផ្តើមយល់ថាមនុស្សផ្សេងទៀតមានចិត្ត និងមានសិទ្ធិ ។
- មានចិត្តរឡេះរឡោះ មានពាក្យប្រស្នា និងនិយាយកំប្លែងលេង ។
- ចូលចិត្តផ្ទាប់ និងឲ្យបានដូចអ្នកឯទៀត។

©2003 First 5 California